គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,
Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធុន សារាយ**
Mr. THUN Saray
ជាតំណាងទី ១ និង
ជាប្រធាន ADHOC

លោក **សុខ សំអឿន**
Mr. SOK Sam Oeun
ជាតំណាងទី ២ និង
ជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហិរញ្ញិក
និងជានាយក CCPCR

លោក **យៀង វណ្ណា**
Mr. YEANG Vanna
ប្រធាន KKKHRA

លោក **ជីវ យូម៉េង**
Mr. CHIV You Meng
ប្រធាន KYA

លោកស្រី **ពឹង យក់ហៀប**
Ms. PEUNG Yok Hiep
នាយិកា LAC

លោក **យង់ គិមអេង**
Mr. YONG Kim Eng
ប្រធាន PDP Center

លោក **ទូច ទុម្ព**
Mr. TOUCH Tum
នាយក VIGILANCE

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

នាយិកា CWCC

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith
**ឥស្សរជន**

លោក **សឺន សែត**
Mr. SEN Set
**ឥស្សរជន**

ស.ប្រ.ក/លេខ ១៩/០៧ គ.ប.ស.យ/អ.ក

# របាយការណ៍បឋមលើកទី ១
# ស្តីពី
# ភាពមិនប្រក្រតីនៅក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០០៧*

ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៧ ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ នេះ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល បាននឹងកំពុងដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួនប្រមាណ **២០០នាក់** ដែលធ្វើការសង្កេតការណ៍ទៅលើ **ឃុំ/សង្កាត់ចំនួន ៤០០** ទូទាំង ២៤ ខេត្ត/ក្រុង[១] ។

គណៈកម្មាធិការ ខុមហ្វ្រែល សង្កេតឃើញជាទូទៅថា **បរិយាកាសនយោបាយ និងសន្តិសុខក្នុងកំឡុងពេលនេះមានសភាពល្អ** បើទោះបីជាប្រជាពលរដ្ឋមួយចំនួនធ្លាប់មានអារម្មណ៍ និងព្រួយអំពីបញ្ហាអសន្តិសុខ ដូចក្នុងកំឡុងមុនពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមុនៗក៏ដោយ។ ខុមហ្វ្រែល **សូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងមន្ត្រីគ្រប់លំដាប់ថ្នាក់ ជាពិសេសអាជ្ញាធរភូមិ ឃុំ/សង្កាត់ ដែលបាន និងកំពុងអនុវត្តការងារចុះឈ្មោះអ្នកបោះឆ្នោតនេះ នៅឃុំ/សង្កាត់មួយចំនួនស្ទើរ និងក្រុមប្រឹក្សាឃុំ/សង្កាត់បានសហការបង្កើតក្រុមចល័តចុះឈ្មោះបោះឆ្នោតទៅដល់ភូមិ។**

ទោះជាយ៉ាងនេះក៏ដោយ ខុមហ្វ្រែល សង្កេតឃើញថា **ល្បឿននៃដំណើរការចុះឈ្មោះបោះឆ្នោតនៅឆ្នាំនេះមានកម្រិតធ្លាក់ចុះ** បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦។ យោងតាម គ.ជ.ប គិតមកត្រឹមថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៧ នេះ នៅក្នុង **១.៦០៨ ឃុំ/សង្កាត់** ទូទាំង ២៤ ខេត្ត/ក្រុង មានប្រជាពលរដ្ឋប្រមាណតែ **២៣៣.៧៧៦ នាក់** បានមកចុះឈ្មោះបោះឆ្នោតថ្មី ស្មើនឹង **៣៤%** នៃចំនួនប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតប៉ាន់ស្មានសរុបរបស់ គ.ជ.ប ដែលមានចំនួនប្រមាណ **៦៨២.៤៥៩ នាក់**[២] ។ ចំណែកនៅក្នុងរយៈពេលដូចគ្នានៃឆ្នាំ **២០០៦** កន្លងមក

---

[១] អ្នកសង្កេតការណ៍ម្នាក់ សង្កេតពីរ ឃុំ/សង្កាត់។

[២] ប្រ.ក/លេខ ០៩.០២២/០៧ គជប.អគ្គ.ពស ស្តីពីលទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះ-ឆ្នោត ប្រចាំឆ្នាំ ២០០៧ ចុះថ្ងៃទី ២៨ កញ្ញា ២០០៧។

អត្រាអ្នកចុះឈ្មោះមានរហូតដល់ជាង ៤៧% (ចុះឈ្មោះបាន ២៧៣.៤៧៧ នាក់ ក្នុងចំណោមអ្នកត្រូវចុះឈ្មោះ ៥៧៧.២០៥នាក់)។

ទន្ទឹមនឹងនេះ ខុមហ្វ្រែល ក៏នៅមានមន្ទិលសង្ស័យចំពោះការប៉ាន់ស្មានតួលេខមិនច្បាស់លាស់របស់ គ.ជ.ប ចំពោះអ្នកត្រូវចុះឈ្មោះ និងអត្រាអ្នកចុះឈ្មោះបោះឆ្នោត ព្រោះនៅក្នុងឆ្នាំ ២០០៦ គ.ជ.ប បានប៉ាន់ស្មានថា មានអ្នកមិនទាន់ចុះឈ្មោះបោះឆ្នោតប្រមាណជា ៥៧ ម៉ឺននាក់ ប៉ុន្តែនៅពេលចុះឈ្មោះបោះឆ្នោត មានអ្នកបោះឆ្នោតជាង ១ លាន ២ សែន នាក់បានចុះឈ្មោះ។ គ.ជ.ប ធ្លាប់បានអះអាងថា តួលេខដែលចុះលើសផែនការ គឺមួយចំនួនដោយសារ មូលហេតុដូចជា អ្នកផ្លាស់ប្តូរទីលំនៅចុះឈ្មោះនៅកន្លែងថ្មី ដោយមិនរាយការណ៍ឱ្យលុបនៅកន្លែងចាស់ដែលធ្វើឱ្យមានឈ្មោះស្ទួនប្រមាណ ១% ដែលស្មើនឹងប្រមាណ ៧ ម៉ឺន ៨ ពាន់ នាក់។

ក្នុងឆ្នាំ ២០០៧ នេះ គ.ជ.ប បានធ្វើយុទ្ធនាការទ្រង់ទ្រាយធំមួយ ដើម្បីសម្អាតបញ្ជីឈ្មោះបោះឆ្នោត ដែលមានឈ្មោះអ្នកបោះឆ្នោតប្រមាណ ៦៥ ម៉ឺននាក់អាចនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត។ តាមការប៉ាន់ប្រមាណស្ថិតិរបស់ គ.ជ.ប អ្នកដែលនឹងត្រូវចុះឈ្មោះបោះឆ្នោត ក៏នៅមានច្រើនដដែលរហូតដល់ជាង ៦៨ ម៉ឺននាក់ **ហើយ គ.ជ.ប នៅមិនទាន់មានការពន្យល់ច្បាស់លាស់ចំពោះបញ្ហាតួលេខប៉ាន់ប្រមាណ និងភាពត្រឹមត្រូវនៃស្ថិតិនេះនៅឡើយទេ។**

យោងតាមអ្នកសង្កេតការណ៍ ខុមហ្វ្រែល ភាពមិនប្រក្រតីអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលកើតមានឡើងញឹកញាប់ មានដូចជា ការមិនគោរពនីតិវិធី ចូលធ្វើការយឺត សម្រាកយូរ ចេញមុនម៉ោង និងមិនបិទបញ្ជីឈ្មោះបោះឆ្នោត និងបញ្ជីរាយនាមអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ទម្រង់ ១០២៥) ពីសំណាក់មន្ត្រីទទួលបន្ទុក។

ជាឧទាហរណ៍ជាក់ស្តែងនៅ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប រហូតមកដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ទើបមន្ត្រីទទួលបន្ទុកធ្វើការបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតចុងក្រោយឆ្នាំ ២០០៦។ ដោយឡែកនៅសង្កាត់អូរជ្រៅ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មេភូមិ និងអនុភូមិកោះខ្យង បានដើរស្រង់ឈ្មោះប្រជាពលរដ្ឋមួយចំនួនទៅចុះឈ្មោះបោះឆ្នោត ដោយយកប្រាក់ពីប្រជាពលរដ្ឋក្នុងម្នាក់ ៣.០០០រៀល។

មានករណីមួយដាច់ដោយឡែក ដែល ខុមហ្វ្រែល បានសង្កេតឃើញ គឺមានទាហាន ៥ នាក់ ប្រដាប់ដោយអាវុធនៃវរៈលេខ ២ ចំណុះតំបន់ប្រតិបត្តិសឹករង ខេត្តបាត់ដំបង បានផ្តល់យោបល់ដល់ប្រជាពលរដ្ឋ ដែលខ្លះមិនទាន់មានឯកសារគ្រប់គ្រាន់ មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ករណីនេះកើតមាននៅក្នុងតំបន់បឹងប្រាំ (ចន្លោះ ឃុំបវេល ឃុំល្វា និងឃុំព្រៃខ្ពស់ ស្រុកបវេល)។ ជាមួយគ្នានេះ ខុមហ្វ្រែល ក៏បានរកឃើញភាពមិនប្រក្រតីមួយផ្សេងទៀតបានកើតឡើងនៅក្នុងស្រុកមេមត់ ទៅក្នុងឃុំចំនួនបី គឺឃុំត្រមូង ឃុំដា និងឃុំមេមត់ អំពីការប្រែប្រួលតួលេខក្នុងទំរង់ ១០២៥ ក្នុងនោះចំពោះឃុំត្រមូង ឈ្មោះអ្នកបោះឆ្នោត តាមតួលេខផ្តល់ឱ្យដោយឃុំ មានចំនួន ៣៤១ នាក់ តែនៅពេលបញ្ជូនត្រឡប់ពី គ.ជ.ប មកវិញចំនួនឈ្មោះខាងលើនេះ បានកើនឡើងរហូតដល់ ៨៤៤ នាក់។ ចំពោះឃុំដា ចំនួនឈ្មោះនេះបានប្រែប្រួលពី ៣១៤នាក់ ទៅដល់ ៨២៦នាក់ និងឃុំមេមត់ បានប្រែប្រួលពី ១៣៤ នាក់ ទៅដល់ ៦៣៤ នាក់ បញ្ហានេះត្រូវបានមន្ត្រីលេខាធិការដ្ឋានខេត្ត

កំពង់ចាម បកស្រាយថា ជាការប៉ាន់ស្មានរបស់ខ្លួន ដោយសារតែកាលពីពេលបោះឆ្នោតឃុំកន្លងមក នៅឃុំទាំងនោះ មានចំនួនអ្នកចេញទៅបោះឆ្នោតទាបពេក។

ចំពោះករណីផ្សេងមួយទៀតដែលប្រជាពលរដ្ឋត្រូវបានជម្លៀសចេញពីភូមិ១៤(ភូមិសំបុកចាប) សង្កាត់ទន្លេបាសាក់ ទៅកាន់សហគមន៍ អណ្តូងថ្មី សង្កាត់គោករកា ខណ្ឌដង្កោ មានចំនួន ៨០២គ្រួសារ មនុស្សសរុបចំនួន ៣.២០២នាក់ ក្នុងនោះប្រជាពលរដ្ឋ ដែលមាន**អាយុ១៨ឆ្នាំឡើងមានចំនួន១.៧១៥នាក់**។ គិតមកដល់ថ្ងៃទី២៦ ខែកញ្ញា ប្រជាពលរដ្ឋទាំងនោះបានទៅ**ចុះឈ្មោះបោះឆ្នោតប្រមាណតែជាង ៣៥០នាក់** ស្មើនឹង ២០.៤០% ប៉ុណ្ណោះ។ ខុមហ្វ្រែលបន្តឃ្លាំមើល ហើយខិតខំជំរុញឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះ បើទោះបីអាជ្ញាធរនៅបន្តអះអាងថា ពលរដ្ឋទាំងនោះគ្មានឯកសារបញ្ជាក់អត្ត-សញ្ញាណគ្រប់គ្រាន់ ឬ ដោយសារមូលហេតុផ្សេងៗក៏ដោយ។

ដោយនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតមានភាពស្មុគស្មាញ ខុមហ្វ្រែល ក៏នឹងបន្តរួមចំណែកធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងមធ្យោបាយអប់រំផ្សេងៗទៀត ដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងស៊ីជម្រៅមិនភាន់ច្រឡំ ហើយបែរមកយកចិត្តទុកដាក់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

គ.ជ.ប ក៏គួរពិនិត្យលទ្ធភាពបង្កើនល្បឿនចុះឈ្មោះអ្នកបោះឆ្នោត ជាពិសេសការពង្រឹងវិន័យរបស់ស្មៀនឃុំ/សង្កាត់ក្នុងការគោរពម៉ោងពេលចូល និងចេញធ្វើការក្នុងកំឡុងមុន និងក្រោយពេលភ្ជុំបិណ្ឌ និងបង្កើនដំណើការចុះឈ្មោះចល័តនៅតាមភូមិឱ្យបានច្រើន។

*សម្រាប់ព័ត៌មានលម្អិតសូមទាក់ទង:*

- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១
- លោក **កុយ ចំន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១

*គណៈកម្មាធិការ ខុមហ្វ្រែល មានបេសកកម្មជួយបង្កើតបរិយាកាសយោគយល់ និងដឹងឮសុះសាយ ១- ដល់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ តាមរយៈការបញ្ចុះបញ្ចូល និងការតស៊ូមតិ ឱ្យមានគម្រោងការគតិយុត្តិសមស្របមួយ មានការអប់រំ ផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីសិទ្ធិរបស់ពួកគេ និងមានសកម្មភាពអង្កេតឃ្លាំមើលដែលកាត់បន្ថយភាពមិនប្រក្រតី ហើយផ្តល់ទិន្នន័យអង្កេត ដែលអនុញ្ញាតឱ្យមានការវាយតម្លៃមិនលម្អៀង និងជាក់ច្បាស់ចំពោះដំណើរការបោះឆ្នោត។ ២- សម្រាប់សារៈសំខាន់ប្រកបដោយអត្ថន័យនៅក្រោយការបោះឆ្នោត តាមរយៈការអប់រំ និងវេទិកាសាធារណៈនានា ដើម្បីជំរុញឱ្យប្រជាពលរដ្ឋចូលរួមក្នុងនយោ-បាយ និងការធ្វើសេចក្តីសម្រេចចិត្ត ការតស៊ូមតិ/បញ្ចុះបញ្ចូល ឱ្យមានកំណែទម្រង់ការបោះឆ្នោត ដែលបង្កើនគណនេយ្យភាពរបស់មន្ត្រីជាប់ឆ្នោត ហើយផ្តល់ឱ្យនូវទិន្នន័យអង្កេត ដែលនាំទៅដល់ការវាយតម្លៃមិនលម្អៀង និងជាក់ច្បាស់ស្តីពីការបំពេញការងារតាមកម្មវិធីនយោបាយរបស់មន្ត្រីជាប់ឆ្នោត។*